ព្រឹទ្ធសភា

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្ដីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែមីនា ឆ្នាំ២០១៦

*នៅក្នុងខែមីនា ឆ្នាំ២០១៦ នេះព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ:*

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន៖**

*-អញ្ជើញជាអធិបតីក្នុងពិធីបំពាក់គ្រឿងឥស្សរិយយសជូន* ***សមាជិក សមាជិកា*** *ព្រឹទ្ធសភា*

*-អញ្ជើញជាអធិបតីក្នុងពិធីបញ្ចុះបឋមសិលាសាងសង់រោងចក្រផលិតស៊ីម៉ង់ត៍របស់ក្រុមហ៊ុន* ***ជីប ម៉ុង អ៊ិនស៊ី ស៊ីមែន ខបភើរេសិន*** *នៅភូមិព្រៃតាព្រិក ឃុំស្ដេចគង់ខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត*

*-អនុញ្ញាតឲ្យលោកស្រី* Rhona Smith *អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ចូលជួបសម្ដែងការគួរសម និងសវនាការ*

*-អនុញ្ញាតឲ្យឯកឧត្តម* Nikolay Fedovow *អនុប្រធានទី១ ក្រុមប្រឹក្សាសហព័ន្ធនៃសភាសហព័ន្ធ នៃសហព័ន្ធរុស្ស៊ីចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ និងអញ្ជើញជាអធិបតីពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងក្រុមប្រឹក្សាសហព័ន្ធនៃសភាសហព័ន្ធ នៃសហព័ន្ធរុស្ស៊ីស្ដីពី " ការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរសភា "*

*-អនុញ្ញាតឲ្យឯកឧត្តម* Ivo SIEBER *ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពស្វីសប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្ដែងការគួរសម និងសវនាការ*

*-អនុញ្ញាតឲ្យឯកឧត្តម* Zenom Kuchciak *ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព*

នៃសាធារណរដ្ឋប៉ូឡូញប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងសវនាការ

-អនុញ្ញាតឲ្យឯកឧត្តម Juan de Jesus Hidalgo-Gato Peres ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋគុយបា ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងសវនាការ

-អនុញ្ញាតឲ្យលោក NORIO YAMAGUCHI អនុប្រធានក្រុមប្រឹក្សាផ្លាស់ប្តូរមិត្តភាពអន្តរជាតិនៃប្រទេសជប៉ុន និងគណៈប្រតិភូចូលជួបសម្តែងការគួរសម និងសវនាការ

-អញ្ជើញដឹកនាំគណៈប្រតិភូសមាជិក សមាជិកាព្រឹទ្ធសភា ដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **ប៉េង ប៉ាត់** សមាជិកគណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈនៃព្រឹទ្ធសភា ដែលបានទទួលមរណភាពកាលពីព្រឹកថ្ងៃទី០២ មីនា ឆ្នាំ២០១៦ ដោយរោគាពាធ

-អញ្ជើញជាអធិបតីក្នុងពិធីបំពាក់គ្រឿងឥស្សរិយយសជាកិច្ចបច្ឆាមរណៈ ដល់សពឯកឧត្តមនាយឧត្តមសេនីយ៍ **ប៉េង ប៉ាត់** សមាជិកព្រឹទ្ធសភា

-អញ្ជើញរំលែកទុក្ខដល់ក្រុមគ្រួសារសពលោកអនុសេនីយ៍ឯក **យ៉ាវ បូរ៉ា** មន្ត្រីនគរបាលចរាចរណ៍ដែលបានទទួលមរណភាពក្នុងពេលបំពេញបេសកកម្ម

-អញ្ជើញចុះសំណេះសំណាល និងសាកសួរសុខទុក្ខមន្ត្រីសង្កាត់ និងបងប្អូនប្រជាពលរដ្ឋ យុវជន ក្នុងសង្កាត់បឹងកាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ

-អញ្ជើញសាកសួរសុខទុក្ខមន្ត្រី និងប្រជាពលរដ្ឋនៅខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣៩ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៤០ច្បាប់ ។

**១.២.ឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ព្រឹទ្ធសភា បាន** :

-អញ្ជើញចូលរួមពិធីជំនួបពិភាក្សាការងាររវាង**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជាជាមួយឯកឧត្តម Nikolay Fedovow អនុប្រធានទី១ ក្រុមប្រឹក្សាសហព័ន្ធនៃសភាសហព័ន្ធ នៃសហព័ន្ធរុស្សី ចូលជួបសម្តែងការ

គួរសម និងពិភាក្សាការងារ និងអញ្ជើញជាអធិបតីពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងក្រុមប្រឹក្សាសហព័ន្ធនៃសភាសហព័ន្ធ នៃសហព័ន្ធរុស្ស៊ីស្តីពី " ការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរសភា "

-អញ្ជើញចូលរួមក្នុងពិធីបញ្ចុះបឋមសិលាសាងសង់រោងចក្រផលិតស៊ីម៉ង់ត៍របស់ក្រុមហ៊ុន **ជីប ម៉ុង អ៊ិនស៊ី ស៊ីមែន ខបភើរេសិន** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៅភូមិព្រៃតាព្រិក ឃុំស្តេចគង់ខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត

-អញ្ជើញជាអធិបតីភាពបើកកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ដើម្បីស្តាប់លទ្ធផលនៃការចុះសិក្សាស្រាវជ្រាវប្រមូលព័ត៌មាននៅខេត្តកែប និងកំពត និងការកំណត់កាលបរិច្ឆេទរៀបចំវេទិកានៅខេត្តកំពត

-អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសំណេះសំណាលជាមួយគណៈប្រតិភូនារីដឹកនាំដោយលោកជំទាវ **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ដើម្បីអបអរសាទរខួបទី១០៥ ទិវាអន្តរជាតិនារី ០៨ មីនា ឆ្នាំ២០១៦ ក្រោមប្រធានបទស្តីពី " វិនិយោគលើសមភាពយេនឌ័រ ដើម្បីកិច្ចអភិវឌ្ឍប្រកបដោយចីរភាព" នៅសាលសិក្ខាសាលាបណ្ណាល័យ

-អញ្ជើញចូលរួមក្នុងពិធីបុណ្យសព និងពិធីបូជាសពឯកឧត្តមនាយឧត្តមសេនីយ៍ **ប៉េង ប៉ាត់** សមាជិកព្រឹទ្ធសភា នៅឈាបនដ្ឋានមុខវត្តបុទុមវត្តី

-អញ្ជើញចូលរួមពិធីលៀងសាយភោជន៍ជាផ្លូវការជាមួយគណៈប្រតិភូក្រុមប្រឹក្សាសហព័ន្ធនៃសភាសហព័ន្ធ នៃសហព័ន្ធរុស្ស៊ី ដឹកនាំដោយឯកឧត្តម Nikolay Fedovow អនុប្រធានទី១ ក្រុមប្រឹក្សាសហព័ន្ធនៃសភាសហព័ន្ធ នៃសហព័ន្ធរុស្ស៊ី នៅសណ្ឋាគារសូហ្វីតែលភូគីត្រាភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន០៦ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១២ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន** :

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបំពាក់គ្រឿងឥស្សរិយយសជូនសមាជិក និងសមាជិកាព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា

-អញ្ជើញជាអធិបតីថ្លែងសុន្ទរកថាបើកសិក្ខាសាលាស្តីពី " **បេតិកភ័ណ្ឌវប្បធម៌អរូបីនៅកម្ពុជា** " នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា

-អញ្ជើញជាអធិបតីថ្លែងសុន្ទរកថាបើកសិក្ខាសាលាហ្វ្រង់កូហ្វូនីស្តីពី " **ទិវាភាសាបារាំង** " និងពិធីជប់លៀងរាត្រីសមោសរមិត្តភាពនៃទិវាភាសាបារាំងនៅព្រឹទ្ធសភា

-អញ្ជើញចូលរួមប្រជុំសមាគមមិត្តភាពកម្ពុជា-ចិន នៅសាលប្រជុំក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ

-អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តទៅពិនិត្យ និងព្យាបាលជំងឺដោយឥតគិតថ្លៃ ព្រមទាំងចែកអំណោយជូនប្រជាពលរដ្ឋ និងសិស្សានុសិស្សនៅឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់

-អញ្ជើញទៅពិនិត្យ និងឧបត្ថម្ភការជួសជុលស្ពានឈើដែលរងការខូចខាតដោយសារភ្លើងឆេះព្រៃនៅឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់

-អញ្ជើញចូលរួមក្នុងពិធីបុណ្យសព និងពិធីបូជាសពឯកឧត្តមនាយឧត្តមសេនីយ៍ **ប៉េង ប៉ាត់** សមាជិកព្រឹទ្ធសភា នៅឈាបនដ្ឋានមុខវត្តបុទុមវត្តី

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១០៤ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២៧ច្បាប់ ។

## ២. គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា :

ក្នុងខែមីនានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម :

### ២.១. មុខងារនីតិកម្ម

-គណៈកម្មការពិសេសប្រជុំពិនិត្យពិភាក្សា និងរៀបចំសេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ឯកសារ និងនីតិវិធីពាក់ព័ន្ធ ។

### ២.២. មុខងារតំណាង

-បានទទួលពាក្យបណ្តឹងចំនួន១០ករណី ធ្វើលិខិតអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយចំនួន០៧ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងបានចំនួន០៧ករណី ទទួលលិខិតឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០១ករណី និងទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធចំនួន០៩ករណី

-ក្រុមសមាជិកាព្រឹទ្ធសភាប្រចាំភូមិភាគទី៤ បានរៀបចំវេទិកាថ្នាក់ខេត្តស្តីពី "ការអនុវត្តមុខងារ និងនីតិវិធីនៃការប្រើប្រាស់ថវិកាគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ" នៅខេត្តបាត់ដំបង

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ រៀបចំវេទិកាថ្នាក់ស្រុកស្តីពី " ពិគ្រោះយោបល់ដើម្បីផ្សព្វផ្សាយនូវសមិទ្ធផលសំខាន់របស់ព្រឹទ្ធសភា និងស្វែងយល់បញ្ហាប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅស្រុកបាភ្នំ ខេត្តព្រៃវែង

-រៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី " សហជីព " សិក្ខាសាលាស្តីពី " ទស្សនវិស័យនៃភាសាបារាំងនៅកម្ពុជា" និងសិក្ខាសាលាស្តីពី "បេតិកភណ្ឌវប្បធម៌អរូបីនៅកម្ពុជា"

-អញ្ជើញចុះស្រាវជ្រាវប្រមូលព័ត៌មាននៅខណ្ឌឬស្សីកែវ ខណ្ឌព្រែកព្នៅ និងខណ្ឌ៧មករា សម្រាប់ត្រៀមលក្ខណៈក្នុងការរៀបចំវេទិកាក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ រាជធានីភ្នំពេញ

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ភូមិភាគទី៤ ប្រជុំពិភាក្សាអំពីគម្រោងរៀបចំវេទិកានៅរាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ និងបញ្ហាផ្សេងៗ

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ប្រជុំរាយការណ៍អំពីលទ្ធផលនៃការចុះសិក្សាស្រាវជ្រាវប្រមូលព័ត៌មាន និងកំណត់កាលបរិច្ឆេទរៀបចំវេទិកានៅខេត្តកែប

-ប្រជុំផ្ទៃក្នុងគណៈកម្មការ ស្តីពីការរៀបចំគម្រោងចុះបេសកកម្មរបស់គណៈកម្មការទី៥ ព្រឹទ្ធសភា នៅពេលវិស្សមកាលរបស់គណៈកម្មការនាពេលខាងមុខ

-ប្រជុំពិនិត្យឯកសារវីដេអូប្រចាំឆ្នាំ២០១៥ស្តីពី " ព្រឹទ្ធសភាឆ្នាំទី២ នីតិកាលទី៣"

-ប្រជុំពិភាក្សាជាមួយវិទ្យាស្ថានសភាកម្ពុជាស្តីពីដំណើរទស្សនកិច្ចរបស់គណៈកម្មការទី១០ទៅប្រទេសឥណ្ឌា និងការត្រៀមរៀបចំវេទិកានៅខេត្តព្រៃវែង

-ប្រជុំផ្ទៃក្នុងគណៈកម្មការស្តីពីគម្រោងបេសកកម្មស្វែងរកព័ត៌មាននៅខេត្តភូមិភាគឥសាន្ត និងគម្រោងរៀបចំសិក្ខាសាលាជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-ប្រជុំជាមួយក្រុមអ្នកធ្វើការងារពាក់ព័ន្ធនឹងការប្រឆាំងអំពើជួញដូរមនុស្សលើកទី១សម្រាប់ឆ្នាំ២០១៦ និងជាមួយសហគមន៍តំណាងអន្តរជាតិមកពីប្រទេសម៉ាឡេស៊ី

អំពីការងារមនុស្សធម៌នៅកម្ពុជា

-ជួបសវនាការជាមួយលោកស្រី Rohna Smith អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា

-ជួបពិភាក្សាការងារជាមួយលោកPark Soo Min នាយកនៃធនាគារអភិវឌ្ឍន៍ និងជាសមាជិកអចិន្ត្រៃយ៍នៃធនាគារ ABLD ក្នុងគោលបំណងសិក្សាស្វែងយល់ពីស្ថានភាពកសិកម្ម សេដ្ឋកិច្ច និងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា និងកម្មវិធីបណ្តុះបណ្តាលផ្សេងៗ

-ជួបពិភាក្សាការងារជាមួយ UN Habitat អំពីកម្មវិធីលំនៅដ្ឋានតម្លៃទាបដើម្បីប្រជាពលរដ្ឋក្រីក្រកាន់តែមានលទ្ធភាពទទួលបានផ្ទះស្នាក់នៅសមរម្យ

-ជួបពិភាក្សាការងារជាមួយលោក **ហា កាន់** ប្រធានវិទ្យាស្ថានសន្ទនាមេគង្គ អំពីការរៀបចំព្រឹត្តិការណ៍មហោស្រពសិល្បៈវប្បធម៌នៅមជ្ឈមណ្ឌលពិព័រណ៍កោះពេជ្រ

-អនុញ្ញាតឲ្យគណៈប្រតិភូហុងគ្រី ចូលជួបពិភាក្សាក្នុងគោលបំណងដើម្បីរកឱកាសបណ្តាក់ទុនវិនិយោគលើវិស័យកសិកម្មនៅកម្ពុជា

-ឆ្លើបទសម្ភាសន៍ទាក់ទងនឹងការវិនិយោគ បញ្ហាប្រឈម ទស្សនវិស័យ និងបញ្ហាផ្សេងៗ

-ស្តាប់បទបង្ហាញពីតំណាងវិទ្យាស្ថានសភាកម្ពុជា (PIC)ស្តីពីបញ្ហាប្រឈមនៃការផ្តល់សេវារដ្ឋបាលនៅថ្នាក់ឃុំ-សង្កាត់ នៅក្នុងស្រុកបាភ្នំ ខេត្តព្រៃវែង

-ចូលរួមសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៦ លើប្រធានបទ "ជំរុញការងារទៅមុខហេដ្ឋារចនាសម្ព័ន្ធនៅក្នុងប្រទេស និងក្នុងតំបន់ និងឡូជីស្ទីកសម្រាប់ការតភ្ជាប់កំណើន និងអភិវឌ្ឍន៍"

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេសចំនួន១២២លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ - សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៨៨លើក។

**៣. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-ឯកឧត្តម **យ៉ង់ សែម** និងលោកជំទាវ **ពុំ ស៊ីចាន់** អញ្ជើញចូលរួមប្រជុំមហាសន្និបាតសហភាពអន្តរសភា (IPU) លើកទី១៣៤ នៅទីក្រុង Lusaka ប្រទេស Zambia ។

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែមេសាឆ្នាំ២០១៦

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

*ចម្លងជូន:*

- *ក្រសួងព្រះបរមរាជវាំង*
- *ក្រុមប្រឹក្សាធម្មនុញ្ញ*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *ក្រសួងយុត្តិធម៌*
- *ក្រសួងព័ត៌មាន*
- *(ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)*
- *កាលប្បវត្តិ-ឯកសារ*